# សេចក្តីថ្លែងការណ៍រួម

## *សង្គមស៊ីវិលកម្ពុជាអបអរសាទរខួបលើកទី៦១ នៃ ទិវាសិទ្ធិមនុស្សអន្តរជាតិ*

## ១០ ធ្នូ ១៩៤៨ - ១០ ធ្នូ ២០០៩

នៅក្នុងឱកាសទិវាសិទ្ធិមនុស្សអន្តរជាតិ ខួបលើកទី៦១ នៃសេចក្តីប្រកាសជាសាកលស្តីពី សិទ្ធិមនុស្ស សង្គមស៊ីវិលកម្ពុជា រួមជាមួយនឹងអង្គការអន្តរជាតិ សូមចូលរួមអបអរសាទរយ៉ាងជ្រាលជ្រៅ និង ប្រកបដោយបេតិសោមនស្សជាខ្លាំង ក្រោមប្រធានបទ “**យើងទាំងអស់គ្នាត្រូវការសេរីភាពបញ្ចេញមតិ និងយុត្តិធម៌** ” និង “**ទទួលយកភាពខុសគ្នា និងបញ្ចប់ការរើសអើង**” នៅក្នុងទូទាំងព្រះរាជាណាចក្រកម្ពុជា។

នៅក្នុងទិវានេះដែរ អង្គការសង្គមស៊ីវិលទាំងអស់ក៏សូមចូលរួមរំលឹកដឹងគុណដល់វិញ្ញាណក្ខ័ន្ធរបស់វីរៈបុរសនៅលើពិភពលោក ក៏ដូចជានៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលបានលះបង់អាយុជីវិតកំលាំងកាយ កំលាំងចិត្តក្នុងបុព្វហេតុ និងចលនាការពារសិទ្ធិសេរីភាពរបស់មនុស្សជាតិ នាពេលកន្លងមក។

សេចក្តីប្រកាសជាសាកល ស្តីពី សិទ្ធិមនុស្ស ត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ កាលពីថ្ងៃទី១០ ធ្នូ ឆ្នាំ១៩៤៨។ សេចក្តីប្រកាសជាសាកលនេះ បានទទួលស្គាល់នូវសិទ្ធិ និងសេរីភាពជាមូលដ្ឋានរបស់មនុស្សទាំងអស់ ទាំងស្ត្រី និងបុរស នៅគ្រប់ទីកន្លែងទាំងអស់នៅក្នុងទូទាំងពិភពលោក ដោយមិនមានការរើសអើងអ្វីទាំងអស់។ ចាប់តាំងពីត្រូវបានអនុម័តនៅឆ្នាំ១៩៤៨ រួចមក សេចក្តីប្រកាសជាសាកលនេះ ត្រូវបានចាត់ទុកថាជា “*បទដ្ឋានសាកលមួយ នៃ សមិទ្ធផលរបស់មនុស្សគ្រប់ប្រជាជាតិទាំងអស់*”។

នៅក្នុងឱកាសទិវាសិទ្ធិមនុស្ស លើកទី៦១ នេះផងដែរ លោកស្រីឧត្តមស្នងការ Navi Pillay នៃការិយាល័យឧត្តមស្នងការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ បានមានប្រសាសន៍ថា គោលបំណង នៃការប្រារព្ធធ្វើទិវាសិទ្ធិមនុស្ស នៅឆ្នាំ២០០៩ នេះ គឺ “*ដើម្បីលើកស្ទួយឱ្យមានសង្គមដែលមិនមានការរើសអើង និងពិភពលោកមួយដែលមានការប្រព្រឹត្តដោយស្មើភាពគ្នាសំរាប់ទាំងអស់គ្នា*” ដែលមានន័យថា មនុស្សទាំងអស់កើតមកមានសេរីភាព និងសមភាពប្រកបដោយភាពថ្លៃថ្នូរ និងមានសិទ្ធិពេញលេញ។ បើទោះបីជា នៅក្នុងសេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស កាលពី៦០ឆ្នាំមុន បានបង្កើតឱ្យមានមូលដ្ឋានជាក់លាក់ជាច្បាប់សិទ្ធិមនុស្សអន្តរជាតិក៏ដោយ ក៏ប៉ុន្តែ សព្វថ្ងៃនេះ អំពើរំលោភសិទ្ធិមនុស្ស និងការរើសអើងប្រឆាំងនឹងមនុស្សរាប់លាននាក់នៅក្នុងពិភពលោក នៅតែបន្តកើតមាន ដែលយើងទាំងអស់គ្នាចាំបាច់ត្រូវតែតស៊ូពុះពារប្រយុទ្ធប្រឆាំងថែមទៀត។

ដោយឡែក ព្រះរាជាណាចក្រកម្ពុជាយើងវិញ ក៏បានចែង និងទទួលស្គាល់ថា សេចក្តីប្រកាសជាសាកលនេះ គឺជាផ្នែកមួយនៃច្បាប់ជាតិរបស់ខ្លួន ជាក់ស្តែងមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញចែងថា: “*ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្ស ដូចមានចែងនៅក្នុងធម្មនុញ្ញ នៃ អង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសាកល ស្តីពី សិទ្ធិមនុស្ស និងកតិកាសញ្ញាព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និង សិទ្ធិកុមារ*”។

សង្គមស៊ីវិលកត់សំគាល់ឃើញថា មានការរីកចំរើនជាវិជ្ជមានមួយចំនួន ជុំវិញការគោរព និងការ លើកស្ទួយសិទ្ធិមនុស្ស នៅក្នុងព្រះរាជាណាចក្រកម្ពុជា នៅខណៈពេលមានចំណុចព្រួយបារម្ភជាច្រើនទៀត ដែលក្នុងនោះរួមមានដូចជាៈ ដំណើរការយឺតយ៉ាវនៃកំណែទម្រង់ប្រព័ន្ធតុលាការ និងការបង្កើតច្បាប់ប្រឆាំងនឹងអំពើពុករលួយ, វប្បធម៌និទណ្ឌភាព, ការកើតមានឥតឈប់ឈរនៃការរំលោភយកដី និងការបណ្តេញប្រជាពលរដ្ឋដោយបង្ខំ, ការគំរាមកំហែងសកម្មជនសិទ្ធិមនុស្ស និងអ្នកសំដែងមតិប្រឆាំងរាជរដ្ឋាភិបាល ក៏ដូចជាសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងការបញ្ចេញមតិតាមទីសាធារណៈដែលហាក់ដូចជារួមតូចមកវិញជាងពីមុន។ លើសពីនេះសង្គមស៊ីវិល ក៏សង្កេតឃើញថា មានអំពើរំលោភបំពានសិទ្ធិមនុស្សធ្ងន់ធ្ងរមួយចំនួនផ្សេងទៀតដូចជាៈ អំពើជួញដូរ និងអំពើកេងប្រវ័ញ្ចទៅលើស្ត្រីភេទ និងកុមារ, ការរំលោភសិទ្ធិជនជាតិដើមភាគតិច ជាពិសេសពាក់ព័ន្ធសិទ្ធិមានកម្មសិទ្ធិលើដីសហគមន៍ ការរើសអើងសិទ្ធិជនពិការពីសង្គម ព្រមទាំងសិទ្ធិកម្មករដែលតែងតែទទួលរងនូវការរំលោភសិទ្ធិក្នុងការទាមទារការធ្វើកូដកម្ម និងបាតុកម្មដោយសន្តិវិធី ក៏ដូចជាទាមទារឱ្យគោរពលក្ខខណ្ឌច្បាប់ការងារ ជាដើម។

**ដូចនេះ ដើម្បីឆ្លើយតបទៅនឹងការប្តេជ្ញាចិត្តរបស់កម្ពុជា ដែលបានទទួលស្គាល់ និងលើកកំពស់សិទ្ធិមនុស្សតាមរយៈច្បាប់រដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូលរបស់ខ្លួន យើងជាតំណាងអង្គការសង្គមស៊ីវិលរៀបចំទិវាសិទ្ធិមនុស្សឆ្នាំ២០០៩ ឆ្លៀតក្នុងឱកាស នៃទិវាសិទ្ធិមនុស្សអន្តរជាតិខួបលើកទី៦១ ដ៏ប្រពៃនេះ សូមស្នើសុំ និងអំពាវនាវដល់រាជរដ្ឋាភិបាលកម្ពុជា ជាពិសេស អាជ្ញាធរមានសមត្ថកិច្ចគ្រប់ជាន់ថ្នាក់ ព្រមទាំងស្ថាប័នតុលាការមេត្តាចាត់វិធានការមួយចំនួន ដូចខាងក្រោមនេះ**

- បើកទូលាយសិទ្ធិសេរីភាពក្នុងការសំដែងមតិ និងការជួបប្រជុំជាសាធារណៈ ដើម្បីចូលរួមនៅក្នុងគ្រប់សកម្មភាពអភិបាលកិច្ចសាធារណៈ ក៏ដូចជាជួយលើកស្ទួយ និង ការពារសិទ្ធិមនុស្ស នីតិរដ្ឋ និងលទ្ធិប្រជាធិបតេយ្យ។
- ចាប់យកទស្សនវិស័យថ្មីក្នុងការអភិវឌ្ឍ ដោយយកសេចក្តីសុខនិងផលប្រយោជន៍របស់ប្រជាពលរដ្ឋជាធំ ហើយអភិវឌ្ឍជាជំហានៗ មិនមែនដោយគំហុកហើយធ្វើឱ្យប៉ះពាល់ដល់សង្គម និងបរិដ្ឋានធ្ងន់ធ្ងរនោះទេ។
- បញ្ឈប់ការជម្លៀសប្រជាពលរដ្ឋចេញពីផ្ទះសំបែងដោយបង្ខំនៅក្នុងបញ្ហាទំនាស់ដីធ្លី ដោយរាជរដ្ឋាភិបាលត្រូវមានគោលនយោបាយ ដើម្បីបើកឱកាសឱ្យដល់ជនក្រីក្ររស់នៅទីក្រុង និង ដើម្បីធានាដល់ការមានលំនៅដ្ឋានសមរម្យ ទាំងសុខមាលភាព និងការសិក្សាអប់រំរបស់មនុស្សគ្រប់រូប។
- បង្កើតផែនការអភិវឌ្ឍន៍ទីក្រុង និងសេដ្ឋកិច្ច ដោយរួមបញ្ចូលប្រជាជនដែលរស់នៅចំតំបន់គោលដៅជាចាំបាច់ ព្រោះថា យើងត្រូវការឱ្យមានកិច្ចអភិវឌ្ឍសំរាប់ទាំងអស់គ្នា មិនមែនសំរាប់តែអ្នកវិនិយោគ និងអាជ្ញាធរសាធារណៈ នោះទេ។
- បញ្ឈប់ការប្រើប្រាស់កងកម្លាំងប្រដាប់អាវុធជាមួយនឹងប្រជាពលរដ្ឋ ដោយត្រូវបង្កើនសមត្ថភាពចចារដោយសន្តិវិធី និងអនុវត្តច្បាប់ឱ្យបានពេញលេញ។
- បញ្ឈប់ចាប់ខ្លួនប្រជាពលរដ្ឋស្លូតត្រង់ ដោយសារបញ្ហាវិវាទដីធ្លី និង ផ្តល់យុត្តិធម៌ឱ្យបានស្មើៗគ្នាទៅដល់ជនរងគ្រោះ។

- បង្កើត និង អនុម័ត ច្បាប់ប្រឆាំងអំពើពុករលួយ និងអនុម័តច្បាប់ស្តីពីសិទ្ធិនៃការទទួលព័ត៌មាន ឱ្យបានឆាប់រហ័ស ដើម្បីជំរុញឱ្យមាននីតិរដ្ឋពេញលេញតាមរយៈការពង្រឹងប្រព័ន្ធគ្រប់គ្រងសាធារណៈឱ្យមានប្រសិទ្ធភាព និងគណនេយ្យភាព ចំពោះមុខប្រជាពលរដ្ឋ។

- ពង្រឹងឯករាជ្យភាព និងអព្យាក្រឹតភាព របស់ស្ថាប័នតុលាការគ្រប់ជាន់ថ្នាក់ ដើម្បីធានាឱ្យមានការកាត់ក្តីដោយយុត្តិធម៌ និងមិនលំអៀង។
- លើកស្ទួយ និងគោរពសិទ្ធិកម្មករ ជាពិសេសពង្រឹងការដោះស្រាយវិវាទការងារដោយសន្តិវិធី។
- ពិនិត្យឡើងវិញនូវគោលការណ៍ច្បាប់ដោយបញ្ជាក់ឱ្យច្បាស់ពីនិយមន័យរើសអើងភេទ និងមានវិធានពិសេស សំរាប់លុបបំបាត់នូវរាល់ការរើសអើងប្រឆាំងនឹងស្ត្រីភេទ នៅក្នុងប្រព័ន្ធសាធារណៈទាំងឡាយ។
- ជួយការពារ និងលើកស្ទួយ សិទ្ធិជនជាតិដើមភាគតិច ជនជាតិភាគតិច ដែលនៅរស់នៅក្នុងប្រទេសកម្ពុជា ឱ្យចៀសផុតអំពីការរើសអើងគ្រប់រូបភាព។
- បញ្ឈប់ និងលុបបំបាត់រាល់ទម្រង់នៃការជួញដូរ និងការកេងប្រវ័ញ្ចទៅលើស្ត្រី និងកុមារ ដោយដាក់ទណ្ឌកម្មទៅលើអ្នកទិញសេវានៃអាជីវកម្មជួញដូរនេះ។
- ជំរុញឱ្យមានការអនុវត្តន៍ប្រកបដោយប្រសិទ្ធភាពនូវច្បាប់ស្តីពីកិច្ចការពារ និងលើកកំពស់សិទ្ធិជនពិការ។

*ភ្នំពេញ ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០០៩*

<u>សំរាប់ព័ត៌មានលំអិត សូមទំនាក់ទំនង:</u>

- លោក **ធន សារាយ** ប្រធានសំរបសំរួលស្តីទី CHRAC/ប្រធានសមាគម ADHOC ទូរស័ព្ទលេខ: ០១៦ ៨៨០ ៥០៩
- លោក **សុក សំអឿន** នាយកប្រតិបត្តិ CDP ទូរស័ព្ទលេខ: ០១២ ៩០១ ១៩៩
- លោក **ឈិត សំអាត** នាយកប្រតិបត្តិ NGO Forum ទូរស័ព្ទលេខ: ០១២ ៩២៨ ៥៨៥
- លោកស្រី **ធិដា ឃីះ** នាយកប្រតិបត្តិអង្គការ SILAKA ទូរស័ព្ទលេខ: ០១២ ៨៣៨ ៤៦៤
- លោក **អាត់ ធន់** ប្រធានសហភាពការងារកម្ពុជា (CLC) ទូរស័ព្ទលេខ: ០១២ ៩៩៨ ៩០៦
- លោកស្រី **ស៊ុន ចាន់សែន** ប្រធានសមាគមយុវជនខ្មែរ (KYA) ទូរស័ព្ទលេខ: ០១៧ ៧៨៨ ៩៥៥
- លោក **អ៊ូ វីរៈ** ប្រធាន CCHR ទូរស័ព្ទលេខ: ០១២ ៤០៤ ០៥១

## សមាជិកនៃក្រុមការងារនៃអង្គការសង្គមស៊ីវិលរៀបចំពិធីអបអរសាទរទិវាសិទ្ធិមនុស្សអន្តរជាតិ:

១- គណៈកម្មាធិការប្រព្រឹត្តិកម្ម នៃអង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា (CHRAC)

២- វេទិការអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា (NGO Forum)

៣- សហភាពការងារកម្ពុជា (CLC)

៤- គណៈកម្មាធិការលុបបំបាត់រាល់ទំរង់នៃការរើសអើងប្រឆាំងនារីភេទ (CEDAW)

៥- គណៈកម្មាធិការដើម្បីលើកស្ទួយស្ត្រីនៅក្នុងវិស័យនយោបាយ (CPWP)

៦- គណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (CCC)

៧- សម្ព័ន្ធអង្គការក្រៅរដ្ឋាភិបាលដើម្បីដោះស្រាយបញ្ហាកេងប្រវ័ញ្ចផ្លូវភេទលើកុមារក្នុងប្រទេសកម្ពុជា (COSECAM)

៨- គណៈកម្មាធិការដើម្បីបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (COMFREL)

៩- ក្រុមការងារពិសេសសិទ្ធិលំនៅឋាន (HRTF)

១០-គណៈកម្មាធិការអព្យាក្រឹត និងយុត្តិធម៌ដើម្បីបោះឆ្នោតដោយសេរី និងត្រឹមត្រូវនៅកម្ពុជា (NICFEC)

១១- វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ (API)

១២- អង្គការជនពិការកម្ពុជា (CDPO)

១៣- អង្គការស្តារកម្ពុជា (Star Kampuchea)

១៤- ក្រុមប្រឹក្សាយុវជនកម្ពុជា (YCC)

១៥- គណៈកម្មាធិការអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ (NGO CRC)

១៦- គណៈកម្មាធិការកម្ពុជាដើម្បីសិទ្ធិស្ត្រី (CAMBOW)

១៧- គណៈកម្មាធិការយុវជនដើម្បីឯកភាព និងអភិវឌ្ឍន៍ (YCUD)

១៨- អង្គការអ៊ិកផាតកម្ពុជា (ECPAT Cambodia)